# សារាចរលេខ

# ០២៤

# ស្តីពីប្រាក់ឈ្នួល នៃ

# ការងារពេលយប់

ណែនាំនិងឧបត្ថម្ភដោយ

-ឯកឧត្តម ជឹទ សុងហាក់

-ឯកឧត្តម ប៊ុន ហុន ចំនួន៨00$

-ឯកឧត្តម កើត រិទ្ធ

-លោក តាន់ សេណារ៉ុង

ឯកសារនេះត្រូវបានការពារ
ដោយច្បាប់នៃព្រះរាជាណា-
ចក្រកម្ពុជាតាមមាត្រា៣និង
មាត្រា១១ នៃច្បាប់ស្តីពីម៉ាក
ពាណិជ្ជនាម និងអំពើនៃការ
ប្រកួតប្រជែងមិនស្មោះត្រង់
ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០២

www.ekasar.com

00414

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល
វិជ្ជាជីវៈ និងយុវនីតិសម្បទា
លេខ......024......សកបយ.

ភ្នំពេញ,ថ្ងៃទី 19 ខែតុលា ឆ្នាំ ១៩៩៩

# សារាចរ
## ស្តីពី
## ប្រាក់ឈ្នួល នៃការងារពេលយប់

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជំរាបលោក លោកស្រីជាម្ចាស់ និងជានាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលស្ថិតនៅក្នុងដែនអនុវត្ត នៃច្បាប់ស្តីពីការងារ ជ្រាបថា ផ្អែកតាមការកំណត់ នៃច្បាប់ស្តីពីការងារ កម្មករ និយោជិត ដែលធ្វើការនៅពេលយប់ចន្លោះពីម៉ោង ២២ ដល់ ម៉ោង ៥ ភ្លឺ ទោះបីធ្វើការដោយផ្លាស់ប្តូរវេនគ្នាក្តី ទោះបីធ្វើការជាអចិន្ត្រៃយ៍ក្តី កម្មករ និយោជិត ទាំងនោះត្រូវបានប្រាក់ឈ្នួលស្មើ និងពីរដង នៃប្រាក់ឈ្នួលធ្វើការពេលថ្ងៃធម្មតា ដូចគ្នា និងករណីធ្វើការបន្ថែមម៉ោងនៅពេលយប់ដែរ ។
ឧទាហរណ៍: សហគ្រាសមួយមានកម្មករ ១៦ នាក់ ។ កម្មករទាំង ១៦ នាក់នេះ ចែកជាពីរផ្នែក គឺមួយផ្នែកមាន កម្មករ ១២ នាក់ ដែលចែកជា ៣ វេនការងារ ក្នុងមួយវេនមានគ្នា ៤ នាក់ ។ កម្មករផ្នែកទី ១ នេះផ្លាស់ប្តូរវេនគ្នាធ្វើការជូនថ្ងៃជូនយប់ ។ ឯកម្មករមួយផ្នែកទៀតមានគ្នា ៤ នាក់ ចែកជាពីរក្រុម មួយក្រុមមានគ្នា ២ នាក់ ធ្វើការជាអចិន្ត្រៃយ៍ ៨ ម៉ោង នៅពេលថ្ងៃ ហើយមួយក្រុមទៀតមានគ្នា ២ នាក់ដែរតែធ្វើការជាអចិន្ត្រៃយ៍នៅពេលយប់ ។ ចំពោះកម្មករ ផ្នែកទី ១ និងកម្មករ ផ្នែកទី ២ ខាងលើ កម្មករណាធ្វើការចំពេលយប់ដែលមានថិរវេលាចន្លោះពីម៉ោង ២២ ដល់ម៉ោង ៥ ភ្លឺ គឺកម្មករនោះត្រូវបានប្រាក់ឈ្នួលស្មើ និងពីរដងនៃប្រាក់ឈ្នួលធ្វើការពេលថ្ងៃធម្មតា សំរាប់ថិរវេលា នៃការងារពេលយប់នោះ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រីជាម្ចាស់ និងជានាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ទាំងអស់ពិតជាយកចិត្តទុកដាក់អនុវត្តបាន ត្រឹមត្រូវតាមច្បាប់ស្តីពីការងារ ជាមិនខាន ។ ការប្រព្រឹត្តល្មើស និងការកំណត់ខាងលើ និងត្រូវទទួលទោសដូចមាន ចែងក្នុងច្បាប់ស្តីពីការងារ ។/.

www.ekasar.com



រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

អ៊ិត សំហេង

<u>ចម្លងជូន:</u>

-ព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជ្រាប"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍
 "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
 ខេត្ត-ក្រុង "ដើម្បីអនុវត្ត"
-កាលប្បវត្តិ-ឯកសារ